**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

# ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia និង ក្លឹបបាល់ទាត់កំពូលនៅអង់គ្លេស Tottenham Hotspur ប្តេជ្ញាបន្តឧបត្ថម្ភអង្គការផ្កាយសមុទ្រ (ISF Cambodia) ទាំងលើកម្មវិធីអប់រំដល់កុមារ និងពង្រីកលីគបាល់ទាត់យុវជនទៅជា AIA-ISF Youth League Grand Championship

**ភ្នំពេញ ថ្ងៃទី 14 ខែសីហា ឆ្នាំ 2022** – តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រដ៏សំខាន់រវាងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA និងក្លឹបបាល់ទាត់ដ៏ធំនៅអង់គ្លេស Tottenham Hostpur ទឹកប្រាក់ 4ម៉ឺនដុល្លារ ត្រូវបានបរិច្ចាគដល់អង្គការផ្កាយសមុទ្រ (ISF Cambodia) នៅក្នុងព្រឹត្តិការណ៍ប្រកួតផ្តាច់ព្រ័ត្រ លីគយុវជន **AIA-ISF Grand Championship Youth League** ដើម្បីផ្គត់ផ្គង់កម្មវិធីសិក្សាកុមារកម្ពុជាដែលជួបការខ្វះខាតឲ្យបានចូលរៀន ឬត្រឡប់ទៅរៀនបន្តវិញ។

ក្លឹបបាល់ទាត់ Tottenham Hotspur គឺជាដៃគូយុទ្ធសាស្ត្រដ៏សំខាន់ របស់ AIA ដោយស្ថាប័នទាំងពីរចូលរួម លើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជនទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក។

AIA Cambodia និង គ្រូបង្វឹកជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍អន្តរជាតិរបស់ក្លឹបបាល់ទាត់ Tottenham Hotspur បានធ្វើការយ៉ាងសកម្មជាច្រើនឆ្នាំជាមួយបុគ្គលិកអង្គការផ្កាយសមុទ្រ (ISF Cambodia) និងគ្រូបង្វឹកស្ម័គ្រចិត្ត ដើម្បីគាំទ្រគំនិតផ្តួចផ្តើមលើបាល់ទាត់ថ្នាក់មូលដ្ឋានរបស់អង្គការនេះ។

Tottenham Hotspur ក៏ផ្តោតលើការចូលរួមលើកកម្ពស់ការសិក្សារបស់កុមារ ដែលសង្កត់ធ្ងន់លើការអប់រំថ្នាក់ពន្លឿន ជាការអប់រំដែលកុមារក្រីក្រ ដែលមិនធ្លាប់បានចូលរៀន ទទួលបានឱកាសសិក្សាកម្មវិធីសិក្សាជាតិដែលត្រូវឲ្យពួកគេរៀន ពីរថ្នាក់ក្នុងឆ្នាំតែមួយរហូតដល់ពួកគេអាចចូលរៀនថ្នាក់ដែលសមស្របទៅនឹងអាយុរបស់ខ្លួន ក៏ដូចជាចូលរៀននៅសាលារដ្ឋបាន។ កម្មវិធីសិក្សាថ្នាក់ពន្លឿនពិសេសនេះ ផ្តល់នូវកម្មវិធី សិក្សា និងការថែទាំសុខភាព អាហារូបត្ថម្ភ និងការជ្រោមជ្រែងគ្រួសាររបស់កុមារៗដែលមិនធ្លាប់បានទៅសាលារៀន ឬត្រូវបានបង្ខំឱ្យបោះបង់ការសិក្សាដោយបញ្ហាជីវភាពក្រីក្រ។

ទឹកប្រាក់ឧបត្ថម្ភក្នុងឆ្នាំនេះ ជាផ្នែកមួយនៃការប្តេជ្ញាលើភាពជាដៃគូរវាង AIA Cambodia និងក្លឹប Tottenham Hotspur ក្នុងការចូលរួមគាំទ្រជាបន្តបន្ទាប់ដល់អង្គការ ផ្កាយសមុទ្រ (ISF Cambodia)។

កាលពីខែ ឧសភា ឆ្នាំ 2021 ក្លឹបបាល់ទាត់ Tottenham Hotspur បានដាក់ដេញថ្លៃអាវកីឡាករពាក់ក្នុងពេលប្រកួតដែលមានហត្ថលេខាកីឡាករ ដែលនៅលើអាវនោះមាននិមិត្តសញ្ញា (ឡូហ្គោ) ISF ភ្ជាប់ជាមួយពាក្យ 'ពីកម្ពុជាដោយ AIA' ដែលត្រូវបានផ្សព្វផ្សាយទៅកាន់ទូទាំងពិភពលោក។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

នៅឆ្នាំ 2022 នេះលីគយុវជន AIA-ISF Youth League បានតម្លើងថ្នាក់របស់ខ្លួនទៅជា AIA-ISF Grand Championship Youth League ដែលការប្រកួតវគ្គផ្តាច់ព្រ័ត្រ ត្រូវធ្វើឡើងរវាងជើងឯកមកពីតំបន់/ខេត្តទាំង 4 ដូចជាកំពត កំពង់ស្ពឺ សៀមរាប និងភ្នំពេញ។ នេះជាសមិទ្ធផលនៃការប្តេជ្ញាចិត្តរបស់ AIA Cambodia និង អង្គការ ក្នុងការបង្កើនឱកាសឲ្យបានទៅដល់ កុមារកាន់តែច្រើនដើម្បីចូលរួមលេងនៅក្នុងលីគមូលដ្ឋានធំជាងគេរបស់ព្រះរាជាណាចក្រកម្ពុជានេះ។

យើងអាចនិយាយបានថាវាលីគនេះពិតជាមានអត្ថន័យយ៉ាងធំធេង តាំងពីស្ថាប័នទាំងពីរបានចាប់ដៃគូកាលពី 5 ឆ្នាំមុន ក្នុងគោលបំណងបង្កើតឱកាសឱ្យកុមារ និងយុវជនដែលជួបបញ្ហាខ្វះខាតអាចលេងបាល់ទាត់ក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព អំណោយផល និងផ្តល់ឱកាសផ្សារភ្ជាប់ពួកគេទៅក្នុងសង្គមកាន់តែច្រើន។

កុមារ និងយុវជន 2533 នាក់មកពីក្រុមចំនួន 205 បានចូលប្រកួតក្នុងលីគ AIA-ISF Grand Champion Youth League ឆ្នាំ 2022 នេះ ដែលចាប់ផ្តើមតាំងពីខែ កុម្ភ: ដោយមានពីរប្រកួតធ្វើនៅភ្នំពេញ និងមួយប្រកួតៗនៅកំពត សៀមរាប និងកំពង់ស្ពឺ។ ក្រុមដែលឈ្នះមកពីខេត្តនីមួយៗបានធ្វើដំណើរមកប្រកួតដើម្បីដណ្តើមជើងឯកនៅទីលានបាល់ទាត់ ISF Sports Ground នៅថ្ងៃទីនេះ។

ក្នុងចំណោមភ្ញៀវកិត្តិយសដែលបានចូលរួមដ៏ច្រើនកុះករក្នុងព្រឹត្តិការណ៍ប្រកួតជ្រើសរើសជើងឯកនេះ យើងក៏ឃើញមានវត្តមានដ៏ខ្ពង់ខ្ពស់ពីសំណាក់លោកស្រី ពុធ ធីតា សមាជិកគណ:កម្មាធិការប្រតិបត្តិ និងជាអនុប្រធានគណ:កម្មាធិការរៀបចំការប្រកួតកីឡាបាល់ទាត់ស្ត្រីនៃសហព័ន្ធកីឡាបាល់ទាត់កម្ពុជា កញ្ញា Shannon Moloney គ្រូបង្វឹកជាន់ខ្ពស់ផ្នែកអភិវឌ្ឍបាល់ទាត់អន្តរជាតិរបស់ក្រុម Tottenham Hotspur លោក Andrew Loh នាយកប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia បុគ្គលិក និងទីប្រឹក្សាផែនការជីវិត AIA Cambodia ។

គួរកត់សម្គាល់ផងដែរថា កុមារមួយចំនួនដែលធ្លាប់ទទួលបានឱកាសលេង និងឆ្លងកាត់ថ្នាលបណ្តុះបណ្តាលពីលីគនេះ ឥឡូវបានអភិវឌ្ឍខ្លួនក្លាយជាកីឡាករលេងឲ្យក្លឹបអាជីព និងមានឈ្មោះលេងឲ្យក្រុមជម្រើសជាតិផងដែរ។

*លោក Andrew Loh អគ្គនាយកប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia បានមានប្រសាសន៍ថា “AIA មានមោទនភាពយ៉ាងខ្លាំងក្នុងនាមជាដៃគូសំខាន់ដ៏យូរអង្វែងជាមួយក្លឹបបាល់ទាត់ដ៏ធំ Tottenham Hotspur។ ភាពជាដៃគូនេះ គឺជាយាននាំទៅការពង្រឹងទំនាក់ទំនងកាន់តែស្អិតរម្ងួតជាមួយអតិថិជន និងសហគម*

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

***ន៍នានានៅទូទាំងតំបន់ ដែលយើងកំពុងធ្វើប្រតិបត្តិការ រួមទាំងប្រទេសកម្ពុជាផងដែរ។ យើងខ្ញុំពិតជាមានសេចក្តីរំភើបរីករាយក្នុងការបន្តកិច្ចសហការជាមួយនឹងអង្គការផ្កាយសមុទ្រ (ISF Cambodia) ជាអង្គការដែលជួយកុមារ និងយុវជននៅកម្ពុជាដែលជួបការខ្វះខាតតាមរយៈផ្តល់ការសិក្សាអប់រំ និងការផ្គត់ផ្គង់ផ្សេងៗដើម្បីជាទុនឈានទៅរកអនាគតដែលពួកគាត់សមនឹងទទួលបាន។***

***ការចូលរួមជ្រោមជ្រែងលើការអប់រំ និងសេវាថែទាំសុខភាពដល់កុមារនៅកម្ពុជា ជាផ្នែកមួយដ៏សំខាន់នៃយុទ្ធនាការលើគំនិតផ្តួចផ្តើម AIA One Billion របស់ AIA Group ដែលមានគោលបំណងជួយមនុស្ស ១,000,000,000នាក់ (មួយពាន់លាននាក់) នៅអាស៊ីឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ នៅឆ្នាំ ២០៣០។***

## *អំពី អេ អាយ អេ*

*អេ អាយ អេ គ្រុប លីមីតធីត និង សាខា (តទៅហៅថា អេ អាយ អេ “AIA” ឬ គ្រុប “Group”) មានក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅទីក្រុងហុងកុង SAR ប្រទេសថៃ សឹង្ហបូរី ម៉ាឡេស៊ី ចិនដីគោក កូរ៉េខាងត្បូង ហ្វីលីពិន អូស្ត្រាលី ឥណ្ឌូនេស៊ី (ចិន) តៃវ៉ាន់ វៀតណាម ញ៉ូហ្ស៊ីលែន ម៉ាកាវ SAR ប្រ៊ុយណេ កម្ពុជា មីយ៉ាន់ម៉ា ក្រុមហ៊ុនបុត្រសម្ព័ន្ធដែល ៩៩ ភាគរយនៅប្រទេសស្រីលង្កា និង ក្រុមហ៊ុនបណ្តាក់ទុនរួម ៤៩ ភាគរយនៅប្រទេសឥណ្ឌា។*

*ក្នុងពេលបច្ចុប្បន្ន អាជីវកម្មរបស់ក្រុមហ៊ុន គឺដូចគ្នានិង អេអាយអេ ដែលត្រូវបានបង្កើតឡើងលើកដំបូងនៅទីក្រុងសៀងហៃ កាលពីមួយសតវត្សកន្លងទៅក្នុងឆ្នាំ ១៩១៩ ។ ជាក្រុមហ៊ុនឈានមុខគេមួយនៅលើទីផ្សារ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (អតីត-ជប៉ុន) ដោយផ្តោតទៅលើបុព្វលាភធានារ៉ាប់រងជីវិត និង មានតួនាទីនាំមុខគេនៅគ្រប់ទីផ្សារភាគច្រើនរបស់ខ្លួន ។ ក្រុមហ៊ុនមានទ្រព្យសម្បត្តិសរុបចំនួន ៣២៦ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០។*

*អេ អាយ អេ ឆ្លើយតបតាមតម្រូវការនៃប្រាក់សន្សំ និង ការការពាររយៈពេលវែងរបស់ ពលរដ្ឋទូទៅតាមរយៈការផ្តល់នូវផលិតផលដ៏សម្បូរបែប និង សេវាកម្មជាច្រើនរួមមាន ការធានារ៉ាប់រងជីវិត គ្រោះថ្នាក់ ការធានារ៉ាប់រងសុខភាព និង ផែនការសន្សំប្រាក់ ។ ក្រុមហ៊ុនគ្រុប ក៏ផ្តល់ផងដែរនូវប្រាក់អត្ថប្រយោជន៍សម្រាប់បុគ្គលិក ផ្តល់ឥណទានអាយុជីវិត និង សេវាកម្មប្រាក់សោធននិវត្តន៍ ។ តាមរយៈបណ្តាញភ្នាក់ងារ ដៃគូ និង បុគ្គលិកដ៏ទូលំទូលាយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក អេអាយអេ បានផ្តល់ដល់ម្ចាស់ប័ណ្ណធានានូវ ប័ណ្ណធានារ៉ាប់រងរូបវន្តបុគ្គលច្រើនជាង ៣៨ លាននាក់ និង សមាជិកដែលបានចូលរួម ផែនការធានារ៉ាប់រងជាក្រុមជាង ១៦ លាននាក់។*

*អេ អាយ អេ គ្រុបលីមីតធិត (AIA Group Limited) ត្រូវបានដាក់បញ្ចូលក្នុង តារាងនៃក្រុមប្រឹក្សាភិបាលចម្បងនៃគណកម្មាធិការផ្សារមូលបត្រទីក្រុងហុងកុង (Main Board of The Stock Exchange of Hong Kong Limited) ដែលស្ថិតក្រោមច្បាប់ផ្សារមូលបត្រ “១២៩៩” ស្របតាមច្បាប់ស្តីពី ការទទួលប្រាក់តម្កល់នៃសហរដ្ឋអាមេរិក (កម្រិត ១) A (American Depositary Receipts (Level 1) ដែលធ្វើពាណិជ្ជកម្មលើទីផ្សារស្របច្បាប់ (រូបសញ្ញា: “AAGIY”)។*